# ព្រះរាជក្រឹត្យ

**នស/រកត/០៧១៥/ ៦៩៨**

## ស្តីពី
## ការបង្កើតគណៈកម្មការដើម្បីពិនិត្យលក្ខណវិនិច្ឆ័យសម្រាប់ការធ្វើសមាហរណកម្មទៅក្នុងថ្នាក់ និងឋានន្តរស័ក្តិនៃចៅក្រម និងព្រះរាជអាជ្ញា

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៣៩៨ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីឋានន្តរស័ក្តិ និងថ្នាក់សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## ត្រាស់បង្គាប់

**មាត្រា ១**: ត្រូវបានបង្កើតគណៈកម្មការដើម្បីពិនិត្យលក្ខណវិនិច្ឆ័យសម្រាប់ការធ្វើសមាហរណកម្មទៅក្នុងថ្នាក់ និងឋានន្តរស័ក្តិនៃចៅក្រម និងព្រះរាជអាជ្ញា ស្របតាមមាត្រា ១០៨ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលមានសមាសភាព៖

| | | |
|---|---|---|
| ១-ឯកឧត្តម **អង្គ វង្សវឌ្ឍនា** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ប្រធាន |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

| | | |
|---|---|---|
| ២-ឯកឧត្តម ហ៊ី សោភា | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣-លោកជំទាវ ចាន់ សុទ្ធាវី | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៤-ឯកឧត្តម កើត រិទ្ធ | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៥-ឯកឧត្តម សំ ប្រជាមានិត | អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | សមាជិកអចិន្ត្រៃយ៍ |
| ៦-ឯកឧត្តម ច័ន្ទ មនោ | អគ្គលេខាធិការនៃក្រសួងយុត្តិធម៌ | សមាជិក |
| ៧-ឯកឧត្តម ផូវ សំភី | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ | សមាជិក |
| ៨-ឯកឧត្តម ប៉ែន ពេជ្រសាលី | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការនិងព្រហ្មទណ្ឌ | សមាជិក |
| ៩-ឯកឧត្តម កើត សេកាណូ | អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ | សមាជិក។ |

គណៈកម្មការនេះ មានមន្ត្រីរាជការស្ថិតក្នុងក្របខណ្ឌក្រសួងយុត្តិធម៌មួយចំនួនតាមការចាំបាច់ ជាជំនួយការ តាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា ២**: គណៈកម្មការដើម្បីពិនិត្យលក្ខណវិនិច្ឆ័យសម្រាប់ការធ្វើសមាហរណកម្មទៅក្នុងថ្នាក់ និងឋានន្តរស័ក្តិនៃចៅក្រម និងព្រះរាជអាជ្ញា មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

-រៀបចំ និងកំណត់លក្ខណវិនិច្ឆ័យនៃក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់ចៅក្រម និងព្រះរាជអាជ្ញាបច្ចុប្បន្ន ដើម្បីធ្វើសមាហរណកម្មទៅក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី ស្របតាមព្រះរាជក្រឹត្យស្តីពីឋានន្តរស័ក្តិ និងថ្នាក់សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា

-រៀបចំ និងសម្រេចការធ្វើសមាហរណកម្មក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់ចៅក្រម និងព្រះរាជ-អាជ្ញាបច្ចុប្បន្នទៅក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី

-រៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការធ្វើសមាហរណកម្មនេះ ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សម្រាប់ទូលថ្វាយព្រះមហាក្សត្រ ព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-អនុវត្តការងារផ្សេងទៀត តាមការចាំបាច់ ដើម្បីធានាដល់ការធ្វើសមាហរណកម្មចៅក្រម និងព្រះរាជ-អាជ្ញាទៅក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

**មាត្រា ៣**: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤**: ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត/០៧១៥/៧០៤

លេខ: ៧១៩ ស.ណ

**សំណៅចែលមានឥម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១៥

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**